# ជំងឺជ្រុះស្លឹករដូវភ្លៀង

## ១.លក្ខណៈទូទៅរបស់ជំងឺ

ជំងឺជ្រុះស្លឹករដូវភ្លៀង បង្កឡើងដោយផ្សិតឈ្មោះ *Phytophtora palmivora, P. meadii, P. bortryosa*។ លក្ខខណ្ឌសមស្របសម្រាប់ជំងឺគឺភ្លៀងច្រើន សីតុណ្ហភាពទាប សំណើមខ្ពស់ និងតាម រយៈសត្វល្អិត។ ការបង្ករជំងឺដំបូងគឺនៅលើផ្លែ ហើយបន្ទាប់មកបានរីករាលដាលទៅលើទងស្លឹក ស្លឹក ដើម និងផ្ទាំងមុខចៀរដែលភាគច្រើននៃជំងឺកើតឡើងនៅខែ សីហា កញ្ញា តុលា និងវិច្ឆិកា។ ផ្សិតជំងឺនេះអាចរស់នៅសម្ងំនៅលើដើម ទងស្លឹក និងស្លឹកពីរដូវមួយទៅរដូវមួយបាន នៅពេលដែលលក្ខខណ្ឌអាកាសធាតុអំណោយផល។ ប្រសិនបើជំងឺប្រផេះសកើតមានលើដើមកៅស៊ូច្រើនក្នុងរដូវជ្រុះស្លឹក នោះជំងឺជ្រុះស្លឹករដូវភ្លៀងកើតមានតិច ផ្ទុយទៅវិញបើដើមកៅស៊ូកើតមានជំងឺប្រផេះសតិចនោះនឹងមានកើតជំងឺជ្រុះស្លឹករដូវភ្លៀងច្រើនវិញ។ ពពួកផ្សិត Phytophthora នេះក្រៅពីបង្ហាញរោគសញ្ញាលើស្លឹក ក៏មានបង្ហាញរោគសញ្ញាលើដើមជាលក្ខណៈឆ្នូតខ្មៅ ដែលគេនិយមហៅថា «ជំងឺឆ្នូតខ្មៅ»។

វត្តមានស្នាមឆ្នូតខ្មៅ ដែលបង្កដោយផ្សិតនេះនៅលើមុខចៀរដើមកៅស៊ូត្រូវបានគេរកឃើញជាលើកដំបូងនៅប្រទេសស្រីលង្កា នាដើមទសវត្សឆ្នាំ១៩០០។ ពពួកផ្សិត Phytophthora មានច្រើនប្រភេទ ក្នុងនោះមាន៦ប្រភេទ បង្កឲ្យដើមកៅស៊ូជ្រុះស្លឹកខុសប្រក្រតី ។

**តារាងទី១៖ ភាពផ្សេងគ្នានៃប្រភេទផ្សិតនិងការបង្កជំងឺ**

| ប្រភេទផ្សិត | ប្រទេសបានរាយការណ៍ | ការបង្កជំងឺ |
|---|---|---|
| *P. meadii* | ឥណ្ឌា ស្រីលង្កា ម៉ាឡេស៊ី ថៃ មីយ៉ាន់ម៉ា ចិន នីហ្សេរីយ៉ា | ស្លឹកជ្រុះខុសប្រក្រតី រលួយផ្លែ ឆ្នូតខ្មៅ ស្នាមដំបៅ |
| *P. palmivora* | ម៉ាឡេស៊ី ឥណ្ឌូនេស៊ី ប្រេស៊ីល ចិន ស្រីលង្កា ថៃ វៀតណាម ភីលីពីន នីហ្សេរីយ៉ា លីបៀរ កូស្តារីកា | ជ្រុះស្លឹកខុសប្រក្រតី ស្នាមដំបៅ |
| *P. botryosa* | ថៃ វៀតណាម ម៉ាឡេស៊ី នីហ្សេរីយ៉ា | ជ្រុះស្លឹកខុសប្រក្រតី ស្នាមដំបៅ |
| *P. citrophthora* | អាយវ៉័កូស ប្រេស៊ីល ឥណ្ឌូនេស៊ី ចិន នីហ្សេរីយ៉ា ថៃ | ជ្រុះស្លឹកខុសប្រក្រតី |
| *P. capsici* | ប្រេស៊ីល ចិន នីហ្សេរីយ៉ា | ឆ្នូតខ្មៅ ស្នាមដំបៅ |
| *P. nicotianae* | ចិន នីហ្សេរីយ៉ា | ជ្រុះស្លឹកខុសប្រក្រតី រលួយផ្លែ ឆ្នូតខ្មៅ ស្នាមដំបៅ |
| *P. phaseoli* | ហ្វីលីពីន | Seedling blight |
| *P. hevea* | ម៉ាឡេស៊ី | រលួយផ្លែ ឆ្នូតខ្មៅ |

## ២. រោគសញ្ញាជំងឺ

ជំងឺជ្រុះស្លឹករដូវភ្លៀង Phytopthora កើតមាននៅលើគ្រប់ផ្នែកទាំងអស់នៃសរីរាង្គរបស់កៅស៊ូលើកលែងតែផ្នែកឫស។ ការបង្កជំងឺនឹងចេញរោគសញ្ញាសំខាន់ៗដូចខាងក្រោម៖

**ក. ស្លឹកជ្រុះ**

រោគសញ្ញាកើតលើទងស្លឹកមានស្នាមដំបៅពណ៌ប្រផេះ ឬខ្មៅរីវត្តន៍លើទងស្លឹក និងមានតំណក់ជ័រនៅលើដំបៅ ហើយពេលខ្លះស្លឹកទាំងមូល ប្រែពណ៌ទៅជាលឿងនិងក្រហមមុននឹងជ្រុះ។

**ខ. ផ្លែ**

ដំបូងផ្លែមានដំបៅដែលមានរាងដូចជាតំណក់ទឹកប៉ុនក្បាយម្ទុល បន្ទាប់មក រីវត្តន៍នៅផ្នែកខាងក្រោមពាក់កណ្ដាលផ្លែ ពេលខ្លះមានតំណក់ជ័រកកជាប់នឹងផ្លែ។ បន្ទាប់ពី ២-៣សប្ដាហ៍ផ្លែមានកន្ទួលពណ៌សបង្កដោយស្ព័រហើយចម្លងមេរោគឲ្យស្លឹក។

**គ. ងាប់ពន្លកត្រួយ**

រោគសញ្ញាលេចឡើងនូវដំបៅពណ៌ប្រផេះ ឬខ្មៅនៅលើពន្លកដើមខ្ចី។ មេរោគរាលដាលយ៉ាងឆាប់រហ័សរហូតដល់ផ្នែកនៃដើមនិងបង្កឲ្យងាប់ដើម។ ពន្លកខ្ចីនៃទងស្លឹកកៅស៊ូកំពុងផ្ដល់ផល រងនូវជំងឺនេះក៏អាចងាប់ដែរ។

**ឃ. រលួយសម្បក**

ស្ព័រជ្រាបចូលតាមរយៈស្នាមរបួសដោយការចៀរជ័រ។ រោគសញ្ញាមានដំបៅពណ៌ប្រផេះ ឬខ្មៅនៅជិតមុខចៀរ និងលេចចេញរាងខូងលើផ្ទាំងមុខចៀរ។ ផ្សិតរីករាលដាលនៅក្នុងជាលិកា សម្បកឈើ បន្ទាប់មកធ្វើឲ្យសម្បកប្រេះហើយជ័រជ្រាបចេញ។ នៅពេលសម្បកនិងសាច់ឈើឆ្លងមេរោគ បានបង្ហាញលក្ខណៈឆ្នូតឈរពណ៌ខ្មៅដែលអាចមើលឃើញនៅលើសាច់ឈើ។




*រូបភាពទី១៖ រោគសញ្ញានៃការកើតជំងឺជ្រុះស្លឹករដូវភ្លៀង*

## ៣. ការការពារនិងការព្យាបាល

### ក.ការការពារ

- ដាំក្លូនធន់នឹងជំងឺដូចជា៖ GT 1, PB 260, RRIM 600, PB 217, PB 235…
- ជំរះស្មៅនិងគ្រប់គល់ជុំវិញដើមកៅស៊ូ
- កាត់មែកខ្លះដើម្បីបង្កើនចរន្តខ្យល់ និងធ្វើឲ្យចម្ការស្រឡះល្អ
- មិនត្រូវបើកមុខចៀរជ័រ ឬប្តូរមុខចៀរនៅរដូវភ្លៀង
- ការពារសម្បកកំណើតពីការឆ្លងមេរោគដោយប្រើថ្នាំផ្សិត Ridomil ក្នុងកម្រិត 5g/1l ទឹកបន្ទាប់ពីប្រមូលទឹកជ័រនៅរាល់ថ្ងៃចៀរ ឬប្រើម្សៅ Sandofan ១សប្តាហ៍ម្តងនៅខែឧសភា-កញ្ញា។

### ខ.ការព្យាបាល

**កៅស៊ូមិនទាន់ផ្តល់ផល**

កូនកៅស៊ូងាយរងនូវជំងឺ ដូច្នេះការព្យាបាលជារឿងចាំបាច់ ដោយបាញ់យ៉ាងតិច ១សប្តាហ៍ ម្តងក្នុងរដូវវស្សា នៅប្រភេទថ្នាំដូចខាងក្រោម៖

- កូពើសាន់ដូស Copper Sandoz (Baur & Co.) ក្នុងកម្រិត 3g/1lទឹក
- ប៉េរេនុក Perenox (C.I.C) កម្រិត 3g/1lទឹក
- ហាក្រូសកូពើអុកស៊ីក្លរីត (Harcross Copper Oxychloride) កម្រិត 3g/1l ទឹក
- ឌីតានអឹម៤៥ (Dithane M45) កម្រិត 3g/1l ទឹក
- ម៉ង់កូសែប (Mancozeb) កម្រិត 3g/1l ទឹក
- មេតាលាក់ស៊ីល (Metalaxyl Mz) កម្រិត 0.2%

**កៅស៊ូផ្តល់ផល**

- ផ្អាកការចៀរជ័រលើដើមកៅស៊ូឈឺ
- ប្រើថ្នាំ Ridomil លាបលើផ្ទាំងមុខចៀរក្នុងកម្រិត 5g/1l ទឹក នៅខែឧសភា ដល់កញ្ញា។